# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្ដារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក-អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 28-Feb-2011, 15:42
CMS/CFO: Phok Chanthan

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: **សាធារណៈ/Public**

ស្ថានភាពចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សារណារបស់លោក អៀង សារី គាំទ្របណ្ដឹងជំទាស់របស់ អៀង ធីរិទ្ធ និង នួន ជា ចំពោះចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង
## និង
## សារណារបស់ អៀង សារី ចូលរួមបណ្ដឹងរបស់ អៀង ធីរិទ្ធ ស្នើសុំដកចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដោយដាក់ជំនួសដោយចៅក្រមបម្រុងនៃអង្គជំនុំជម្រះសាលាដំបូង ឬចៅក្រមបន្ថែម តាមការជ្រើសរើសរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ ដើម្បីសម្រេចលើបណ្ដឹងជំទាស់

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវី:** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្ដម | ចៅក្រម **និល ណុន** ជាប្រធាន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម **ឆ្វ មណី** | លោក Andrew CAYLEY |

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **យូរ ឧត្តរា**

ចៅក្រមបម្រុង Claudia FENZ

**ក្រុមមេធាវីការពារក្តីទាំងអស់**

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់ខ្លួន ("មេធាវីការពារក្តី") សូមគាំទ្របណ្តឹងជំទាស់របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងចៅក្រម និល ណុន, ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, និង ចៅក្រម ធូ មណី ("បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ")[1] និងបណ្តឹងជំទាស់បន្ទាន់របស់លោក នួន ជា ចំពោះចៅក្រមអង្គជំនុំជម្រះសាលាដំបូង ("បណ្តឹងជំទាស់របស់ នួន ជា")[2] ( ហៅរួមថា "បណ្តឹងជំទាស់")។ មេធាវីការពារក្តីសូមឯកភាពទៅនឹងបណ្តឹងជំទាស់ដោយហេតុថាយ៉ាងហោចណាស់ មានការលេចចេញនូវភាពលម្អៀងរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ដែលបានកើតមានដោយសារការសម្រេចរបស់ពួកគាត់លើបញ្ហាមួយចំនួនក្នុងសំណុំរឿង ០០១ ដែលនឹងត្រូវពិភាក្សាក្នុងសំណុំរឿង ០០២[3]។ មានសំអាងរឹងមាំក្នុងការអះអាងថា ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនឹងមានផលប្រយោជន៍លើសលប់ក្នុងការធ្វើសំអាងហេតុមួយដែលស្របទៅនឹងសំអាងហេតុរបស់ពួកគាត់ក្នុងសំណុំរឿង០០១ ដោយហេតុថាសំអាងហេតុផ្ទុយគ្នានឹងប៉ះពាល់ទៅដល់ការសម្រេចរបស់ពួកគាត់លើឧក្រិដ្ឋកម្មមួយចំនួន[4] ដែលចំណុចនេះធ្វើឲ្យប៉ះពាល់ដល់ភាពអនាគតិ

---

[1] សំណុំរឿង អៀង ធីរិទ្ធ, 002/19-09-2007-អវតក/កសចស, បណ្តឹងជំទាស់របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងចៅក្រម និល ណុន, ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, និង ចៅក្រម ធូ មណី, ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១១, E28, ERN: 00641075-00641090។

[2] *សូមមើល* សារអេឡិចត្រូនិករបស់ Andrew IANUZZI ជូន Andrew CAYLEY, Karlijn VAN DER VOORT, Vera MANUELLO, Tanya Rene PETTAY, Neville SORAB, Sheherazade BOUARFA, and Eleonor FERNANDEZ, ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ដែលភ្ជាប់មកជាមួយសំណៅថតចម្លងមួយច្បាប់នៃបណ្តឹងជំទាស់របស់ នួន ជា ដែលពុំទាន់ត្រូវបានជូនដំណឹងនៅឡើយមកទល់ពេលនេះ។

[3] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ១, បណ្តឹងជំទាស់របស់ នួន ជា, កថាខណ្ឌ ២។

[4] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ២៤។

របស់ពួកគាត់ នៅពេលពិចារណាឡើងវិញអំពីបញ្ហាណាមួយដែលត្រូវពិភាក្សា[5]។ ដើម្បីជាប្រយោជន៍ដល់យុត្តិធម៌ និងបញ្ចៀសការយល់ខុសណាមួយដែលថាតុលាការពុំមានភាពត្រឹមត្រូវ បណ្តឹងជំទាស់ត្រូវស្តាប់ និងសម្រេច ដោយក្រុមប្រឹក្សាជំនុំជម្រះ ដែលពុំជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០១។ ដូច្នេះ មេធាវីការពារក្តីសូមចូលរួមជាមួយ នឹងបណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ ចំពោះចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដោយដាក់ជំនួសនូវចៅក្រម បម្រុងនៃអង្គជំនុំជម្រះសាលាដំបូង ឬចៅក្រមបន្ថែមតាមការជ្រើសរើសរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ ("JAC") ពីក្នុងចំណោមចៅក្រម អ.វ.ត.ក ដើម្បីសម្រេចលើបណ្តឹងជំទាស់ អនុលោមតាមវិធាន ៣៤(៦) នៃ វិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន")[6]។ មេធាវីការពារក្តីស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធីរហូតដល់ពេលបណ្តឹងជំទាស់ ត្រូវបានដោះស្រាយរួចរាល់ជាស្ថាពរ។ យើងសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបើកសវនាការជាសាធារណៈ។

## I. ច្បាប់ជាធរមាន

### ក. បណ្តឹងជំទាស់ចំពោះចៅក្រម

១. វិធាន ៣៤(២) ចែងថា៖

> ភាគីអាចធ្វើបណ្តឹងជំទាស់ចំពោះចៅក្រមក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់ មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិត ប្រាកដដល់ភាពអនាគតិ ឬអាចបង្កើតឲ្យមានភាពលម្អៀង។

[5] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ១, បណ្តឹងជំទាស់របស់ នួន ជា, កថាខណ្ឌ ៣៣។

[6] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៤១, បណ្តឹងជំទាស់របស់ នួន ជា, កថាខណ្ឌ ២៤, ៣៤។

២. ក្នុងការបកស្រាយវិធាននេះ អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់លក្ខណៈវិនិច្ឆ័យរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការ ICTY ("លក្ខណៈវិនិច្ឆ័យរបស់តុលាការ ICTY")[7] ដែលចែងថា៖

ចៅក្រមមួយរូបមានភាពលម្អៀង ប្រសិនបើភាពលម្អៀងពិតប្រាកដត្រូវបានគេរកឃើញ ។

ភាពលម្អៀងកើតមានក្នុងករណីដែល៖

- ចៅក្រមរូបនោះជាភាគីនៃរឿងក្តី ឬមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬទាក់ទងនឹងកម្មសិទ្ធិដែលបានមកពីរឿងក្តី ឬប្រសិនបើសេចក្តីសម្រេចរបស់ចៅក្រមនោះនឹងនាំឲ្យមានការជួយជម្រុញមូលហេតុនៃការជាប់ពាក់ព័ន្ធរបស់គាត់ទៅនឹងភាគីណាមួយនៃរឿងក្តី។ ក្នុងករណីនេះ គេត្រូវដកចៅក្រមចេញពីរឿងក្តីដោយស្វ័យប្រវត្តិ ឬ

- ករណីទាំងនេះនាំឲ្យអ្នកសង្កេតការណ៍ប្រកបដោយសុភវិនិច្ឆ័យ និងដែលបានទទួលព័ត៌មានត្រឹមត្រូវ យល់ថាមានភាពលម្អៀង[8]។

---

[7] *សំណុំរឿង អៀង សារី,* 002/19-09-2007-អវតក/កសចស, សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ, ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១, E5/3, ERN: 00640427-00640435, ("សេចក្តីសម្រេចលើបណ្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន"), កថាខណ្ឌ ៦។

[8] *វណ្ណអាជ្ញា ទល់នឹង* *Furundžija,* សាលក្រម, IT-95-17/1-A, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០, កថាខណ្ឌ ១៨៩។

៣. យុត្តិសាស្ត្ររបស់ អ.វ.ត.ក បញ្ជាក់ថាបណ្តឹងជំទាស់ចិត្តត្រូវធ្វើចំពោះចៅក្រមណាម្នាក់ដែលកាន់រឿងក្តីណាមួយ ពុំមែនចៅក្រមទាំងអស់ឡើយ[9]។ ទោះបីលក្ខខណ្ឌតម្រូវត្រង់ចំណុចនេះត្រូវបានលុបចេញពីបណ្តឹងជំទាស់ចិត្តក្តី ក៏យើងបានបំពេញតាមលក្ខខណ្ឌតម្រូវនេះរួចហើយ ដោយហេតុថាបណ្តឹងជំទាស់ចិត្ត ទាមទារដកចៅក្រមអង្គជំនុំជម្រះសាលាដំបូងចេញពីសំណុំរឿង ០០២ ដោយសារមានភាពលម្អៀងនៅក្នុងសំណុំរឿងនេះ។

៤. ក្រមសីលធម៌ចៅក្រម អ.វ.ត.ក ចែងថាចៅក្រមត្រូវរក្សានូវភាពមិនលម្អៀងត្រង់ចំណុចថា "ចៅក្រមត្រូវចៀសវាងនូវរាល់ជម្លោះផលប្រយោជន៍ ឬស្ថិតក្នុងស្ថានភាពណាមួយដែលគេអាចយល់ឃើញថាមានទំនាស់ផលប្រយោជន៍កើតឡើង"[10]។

## ខ. តុលាការអាចទទួលយកបាននូវបណ្តឹងជំទាស់ចិត្តតែមួយ ចំពោះចៅក្រមច្រើនរូបដែលស្ថិតនៅរួមគ្នាក្នុងអង្គជំនុំជម្រះមួយ

៥. មាត្រា ៥៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CPC") ចែងថា "កាលណាអ្នកប្តឹងចង់សុំបដិសេធចៅក្រមច្រើនរូបដែលឡើងជំនុំជម្រះនៅក្នុងក្រុមសមូហភាពជាមួយគ្នានោះ អ្នកប្តឹងអាចដាក់ពាក្យប្តឹងតែមួយគត់"។ ទោះបីបណ្តឹងជំទាស់ចិត្តពុំបានលើកឡើងអំពីបញ្ហានេះក្តី ក៏ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាពុំអនុញ្ញាតឲ្យ

---

[9] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន, កថាខណ្ឌ ៩-១១។

[10] ក្រមសីលធម៌ចៅក្រម អ.វ.ត.ក, ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០៨, មាត្រា ២(២)។ ស្រដៀងគ្នានេះ ក្រមសីលធម៌ចៅក្រមកម្ពុជា មាត្រា ១៧ ចែងថា៖ "ប្រសិនបើចៅក្រមមានមូលដ្ឋានច្បាស់ថា ខ្លួនមិនអាចសម្រេចសេចក្តីដោយអនាគតិបានទេ នោះត្រូវដកខ្លួនពីការជំនុំជម្រះដោយផ្អែកតាមក្រមនីតិវិធី"។

អ.វ.ត.ក ចាត់ការបណ្ដឹងជំទាស់ចំពោះចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង ដូចដែលបានរៀបរាប់ក្នុងបណ្ដឹងជំទាស់ឡើយ។

### គ. សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌

៦. លោក អៀង សារី មានសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយចៅក្រមមិនលម្អៀង។ សិទ្ធិនេះមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")[11] និងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ("UDHR")[12] ដែលគេត្រូវគោរព អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[13], កិច្ចព្រមព្រៀង[14], និងច្បាប់ស្ដីពីការបង្កើតឲ្យមាន អ.វ.ត.ក[15]។

---

[11] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR), មាត្រា ១៤ ត្រង់ផ្នែកពាក់ព័ន្ធចែងថា៖ "ក្នុងការសម្រេចសេចក្ដីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ឬពីសិទ្ធិ និងកាតព្វកិច្ច ក្នុងរឿងក្ដីណាមួយ ជនគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះដោយសាលាក្ដីមានសមត្ថកិច្ចឯករាជ្យ មិនលម្អៀងដែលបង្កើតឡើងដោយច្បាប់"។

[12] សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សត្រង់មាត្រា ១០ ចែងថា៖ "មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាពេញលេញ សុំឱ្យតុលាការឯករាជ្យ និងមិនលម្អៀង ពិនិត្យរឿងក្ដីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ និងកាតព្វកិច្ច និងលើភាពសមហេតុផលនៃការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌមកលើខ្លួន"។

[13] រដ្ឋធម្មនុញ្ញកម្ពុជា, ដែលត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ ១៩៩៩, មាត្រា ៣១ ត្រង់ផ្នែកពាក់ព័ន្ធចែងថា៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។

[14] កិច្ចព្រមព្រៀង, មាត្រា ១៣ ត្រង់ផ្នែកពាក់ព័ន្ធចែងថា៖ "សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅគ្រប់ដំណាក់កាលនៃការជំនុំជម្រះ"។

## II. ទឡ្ហីករណ៍

### ក. គាំទ្របណ្តឹងជំទាស់ត្រង់ចំណុចដែលថាចៅក្រមអង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀង

៧. សំណុំរឿង០០១ និង ០០២ មានការពាក់ព័ន្ធគ្នាទាក់ទិននឹងបញ្ហាអង្គហេតុនិងអង្គច្បាប់មួយចំនួន[16]។ ការសម្រេចលើបញ្ហាទាំងអស់ដែលមាននៅក្នុងសំណុំរឿង ០០២ ត្រូវបានធ្វើឡើងដោយចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១[17]។ នៅពេលបច្ចុប្បន្ន ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងស្ថិតក្នុងស្ថានភាពមួយដែលនឹងនាំឱ្យអ្នកសង្កេតការណ៍ប្រកបដោយសុភវិនិច្ឆ័យ និងដែលបានទទួលព័ត៌មានត្រឹមត្រូវ យល់ដោយសមហេតុផលថាមានភាពលម្អៀង។ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងហាក់បីដូចជាសម្រេចគាំទ្រសំអាងហេតុរបស់ខ្លួនរួចជាស្រេចទៅហើយ និងតម្កល់ច្បាប់ដែលមានចែងពាក់ព័ន្ធនឹងសំណុំរឿង០០១ ពុំនោះទេ នឹងធ្វើឱ្យប៉ះពាល់ដល់ភាពយុត្តិធម៌នៃសាលក្រមរបស់ខ្លួនលើសំណុំរឿង ០០១។ បើនិយាយបែបអត្តនោម័ត ចំណុចនេះពុំមានន័យថាអង្គជំនុំជម្រះសាលាដំបូងនឹងពុំខិតខំឱ្យអស់ពីលទ្ធភាពដើម្បីរក្សាភាពមិនលម្អៀងឡើយ។ ប៉ុន្តែ បើគេនិយាយតាមលក្ខណៈសត្យានុម័តវិញ ចំណុចនេះហាក់បីដូចជាបញ្ជាក់ឱ្យឃើញថា លទ្ធភាពដែលអង្គជំនុំជម្រះសាលាដំបូងយកសំអាងហេតុ និងការសម្រេចរបស់ខ្លួនមកពិចារណាឡើងវិញ គឺនៅឆ្ងាយសន្ធឹម។ ដូចដែល Lord Hewart C.J. បានពន្យល់

---

[15] ច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក, មាត្រា ៣៣ ថ្មី ត្រង់ផ្នែកពាក់ព័ន្ធចែងថា៖ "អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចមានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ"។

[16] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៥-១១។ បណ្តឹងជំទាស់របស់ នួន ជា, កថាខណ្ឌ ២-១១ (និងកថាខណ្ឌ ៩-១១ ដែលគោលការណ៍ទាំងនោះអាចយកមកអនុវត្តបានដូចគ្នាចំពោះករណីលោក អៀង សារី)។

[17] បណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៥-១១។ បណ្តឹងជំទាស់របស់ នួន ជា, កថាខណ្ឌ ២-១១។

ច្បាស់ថា "ជាការសំខាន់ណាស់ដែលថាតុលាការមិនត្រឹមតែត្រូវសម្រេចឲ្យបានយុត្តិធម៌ឡើយ ប៉ុន្តែតុលាការត្រូវធ្វើឲ្យគេឃើញច្បាស់ថា ដំណើរការនៃការសម្រេចយុត្តិធម៌ក៏ត្រូវបានធ្វើដោយយុត្តិធម៌ផងដែរ"[18]។

៨. តាមរយៈការកាត់សេចក្តីលើសំណុំរឿង ០០១ ភាពមិនលម្អៀងរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង ០០២ មានភាពចម្រូងចម្រាស ដោយសារកំហុសអចេតនារបស់ខ្លួន ។ ឧទាហរណ៍៖

ក. តើចៅក្រមអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើដូចម្តេចដើម្បីធានាឲ្យប្រាកដថា សំអាងហេតុរបស់ខ្លួនពុំមានវិការៈ ឬហាក់ដូចជាពុំមានវិការៈ ដោយសារខ្លួនមានបំណងចង់ធ្វើសាលក្រមក្នុងសំណុំរឿង០០២ ឲ្យស្របតាមសាលក្រមរបស់ខ្លួនលើសំណុំរឿង ០០១ ពិសេសនៅពេលខ្លួនពិចារណាឃើញថាសាលក្រមលើសំណុំរឿង០០២ នឹងប៉ះពាល់ទៅដល់ភាពអាចជឿទុកចិត្តបាននៃសាលក្រមលើសំណុំរឿង ០០១?

ខ. តើចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើដូចម្តេចដើម្បីធានាឲ្យប្រាកដថាខ្លួនធ្វើ និងហាក់ដូចជាធ្វើសាលក្រម ដោយផ្អែកតែម្យ៉ាងទៅលើភ័ស្តុតាង ដែលបានដាក់ចំពោះមុខខ្លួនក្នុងសំណុំរឿង០០២ នៅពេលខ្លួនធ្លាប់បានសម្រេចសេចក្តីលើបញ្ហាដូចគ្នានេះជាច្រើនក្នុងសំណុំរឿង ០០១?

គ. តើចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើដូចម្តេច ប្រសិនបើភ័ស្តុតាងមួយចំនួនគ្មាននៅក្នុងសំណុំរឿង ០០២ ប៉ុន្តែមាននៅក្នុងសំណុំរឿង ០០១ ហើយចៅក្រមមានបំណងយកភ័ស្តុតាងក្នុងសំណុំរឿង ០០១ មកសំអាងដែរ ឬទេ?

---

[18] *R v Sussex Justices ex parte McCarthy* [1924], 1 KB 256, ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ១៩២៣។

៩. ក្នុងសំណុំរឿង ០០២ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាបានសម្រេចទុកជាមុនថារយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យតុលាការកម្ពុជាធ្លាក់ចុះអន់ខ្សោយ[19]។ សំអាងហេតុនេះស្របទៅនឹងសាលក្រមលើសំណុំរឿង ០០១ ដែលអះអាងថា "នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រព័ន្ធតុលាការដែលអាចផ្តល់ការគាំពារដល់ជនជាប់ចោទតាមនីតិវិធីត្រឹមត្រូវពុំមានដំណើរការឡើយ"[20]។ តាមរយៈនេះ អ្នកសង្កេតការណ៍ប្រកបដោយសុភវិនិច្ឆ័យអាចសន្និដ្ឋានថា បើគិតដល់ជម្រើសរវាងការគាំទ្រការសម្រេចរបស់ខ្លួនក្នុងសំណុំរឿង ០០១ និងការពិនិត្យមើលបញ្ហាទាំងនេះជាថ្មី ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនឹងគាំទ្រការសម្រេចរបស់ខ្លួនក្នុងសំណុំរឿង ០០១។ ទោះបីមានចេតនា ឬគ្មានក្តី ក៏សំអាងហេតុទាំងនេះអាចធ្វើឲ្យអ្នកសង្កេតការណ៍ប្រកបដោយសុភវិនិច្ឆ័យម្នាក់ដែលបានទទួលព័ត៌មានត្រឹមត្រូវ យល់ដោយសមហេតុផលថា មានភាពលម្អៀងក្នុងសំណុំរឿង ០០២។

១០. ប្រសិនបើចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២ និងសំណុំរឿង ០០១ ជាមនុស្សតែមួយ នោះគឺជាការប្រែត្រឡប់ *តាមព្រឹត្តិន័យ* នូវបន្ទុកនៃភ័ស្តុតាង។ ពេលនេះ មេធាវីការពារក្តីនឹងត្រូវធ្វើយ៉ាងណាឲ្យចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងយល់ថា សំអាងហេតុ និងការសម្រេចមុនៗរបស់ពួកគាត់ពុំត្រឹមត្រូវ ហើយពួកគាត់ត្រូវទទួលស្គាល់កំហុស និងត្រូវដកខ្លួនចេញ។ ប្រសិនបើកាតព្វកិច្ចក្នុងការ

---

[19] សេចក្តីសម្រេចលើបណ្តឹងជិតចិត្តចំពោះចៅក្រម និល ណុន, កថាខណ្ឌ ៩។

[20] *សំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ "ឌុច"*, 001/18-07-2007-អវតក/អជសង, សាលក្រម, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, E 188, ERN: 00572517-00572797, កថាខណ្ឌ ៩៤។

ស្វែងរកភ័ស្តុតាងដាក់បន្ទុករបស់ ក.ស.ព ប្រែក្លាយទៅជាកាតព្វកិច្ចរបស់មេធាវីការពារក្តីវិញ នោះជាការរំលោភសច្ចធារណ៍នៃនិរទោសរបស់ លោក អៀង សារី[21]។

១១. បញ្ហាចម្រូងចម្រាសដែលថាចៅក្រមដែលជាអ្នកសម្រេចលើសហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទប្រកាន់ដូចគ្នាក្នុងសំណុំរឿង ២ ដាច់ដោយឡែក គឺជាក្រុមចៅក្រមតែមួយដែលស្ថិតក្នុងអង្គជំនុំជម្រះសាលាដំបូង ត្រូវបានមេធាវីការពារក្តីគូសបញ្ជាក់ជូនអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០១ ដែលក្នុងនោះមេធាវីការពារក្តីបានកត់សម្គាល់ថា៖

> ជនត្រូវចោទក្នុងចំនួនដ៏តិចដែល អ.វ.ត.ក បានជំនុំជម្រះ, ការដែលថាមានតែអង្គបុរេជំនុំជម្រះមួយ និងការដែលថាជនត្រូវចោទជាប់ពាក់ព័ន្ធគ្នាទៅវិញទៅមកមានន័យថា ក្នុងពេលមានសេចក្តីសម្រេចណាមួយមកលើជនត្រូវចោទណាម្នាក់ វានឹងប៉ះពាល់យ៉ាងពិតប្រាកដដល់ជនត្រូវចោទឯទៀត។ ផលប៉ះពាល់នេះត្រូវបានគូសបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះសាលា

---

[21] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨ ចែងថា៖ "ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។ មាត្រា ៣៥ ថ្មីនៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ចែងថា៖ "ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។ វិធាន ២១ (១) (ឃ) ត្រង់ផ្នែកពាក់ព័ន្ធចែងថា៖ "ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ"។ មាត្រា ១៤ (២) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា៖ "ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌត្រូវបានសន្មត់ជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់"។ មាត្រា ១១ (១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សចែងថា៖ "ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌត្រូវសន្មតជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចាំបាច់ ដើម្បីឱ្យជននោះការពារខ្លួន។

ដំបូង ក្នុងករណីចៅក្រមដែលដែលជំនុំជម្រះ *ឌុច* និងដោះស្រាយបញ្ហានេះ នឹងត្រូវជំនុំជម្រះលោក លោក អៀង សារី នៅពេលក្រោយ។ គ្មានលទ្ធភាពដែលថាអង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្តីសម្រេចមួយលើសំណុំរឿង *ឌុច* ស្តីពីលទ្ធភាពក្នុងការអនុវត្ត JCE នៅ អ.វ.ត.ក ហើយបន្ទាប់មកកែប្រែការសម្រេចរបស់ខ្លួននៅក្នុងសំណុំរឿងបន្ទាប់ដែល ក.ស.ព យល់ថាជាផ្នែកមួយនៃសំណុំរឿង *ឌុច* ឡើយ។ ដូច្នេះ សេចក្តីសម្រេចលើសំណុំរឿង *ឌុច* ពាក់ព័ន្ធនឹងលទ្ធភាពក្នុងការអនុវត្ត JCE នៅចំពោះមុខ អ.វ.ត.ក សម្រាប់ចេតនា និងគោលបំណងទាំងអស់ គឺចងភ្ជាប់កាតព្វកិច្ចនៃការខុសត្រូវចំពោះ លោក អៀង សារី ដោយផ្ទាល់ និងជាផ្លូវការ[22]។

១២. ទោះបីសំណើរបស់មេធាវីការពារក្តីក្នុងសំណុំរឿង *ឌុច* ពាក់ព័ន្ធនឹងបញ្ហាអង្គច្បាប់ថាតើសហឧក្រិដ្ឋកម្មរួមគឺជាទម្រង់នៃការទទួលខុសត្រូវជាធរមាននៅ អ.វ.ត.ក ក្តី ក៏គោលការណ៍ដែលខ្លួនប្រកាន់យក គឺអាចយកមកអនុវត្តបានដូចគ្នាចំពោះបញ្ហាអង្គហេតុដែលបានលើកឡើងនៅក្នុងបណ្តឹងជិតចិត្ត។ ចំណុចខុសគ្នាតែមួយគត់គឺថា ភាពលម្អៀងដែលអាចមានដែលមេធាវីការពារក្តីបានដឹងនៅខែមិថុនា ឆ្នាំ២០០៩ ពេលនេះបង្កើតបានជាកាលៈទេសៈមួយ ដែលនាំឲ្យអ្នកសង្កេតការណ៍ប្រកបដោយសុភវិនិច្ឆ័យដែលបានទទួលព័ត៌មានត្រឹមត្រូវ យល់ដោយសមហេតុផលថាមានភាពលម្អៀងក្នុងសំណុំរឿង ០០២។

---

[22] *សូមមើលសំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* , 001/18-07-2007-អវតក/អជសជ, សំណើជាបន្ទាន់របស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តនូវការទទួលខុសត្រូវជាទម្រង់សហឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៩, D99/3/6, ERN: 00223990-00223997, កថាខណ្ឌ ៧។

១៣. ចំណុចដែលថាចៅក្រមប្រើប្រាស់សច្ចាធារណ៍នៃភាពមិនលម្អៀង គឺគេពុំអាចជំទាស់បានឡើយ។ ដូច្នេះ ក្នុងការយល់ថាមានភាពលម្អៀង គេត្រូវមានភស្តុតាងយកមកបញ្ជាក់ឲ្យច្បាស់ ទើបជាការសមហេតុផល។ ទោះបីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងពិតជាបានប្រើប្រាស់ ឬមិនប្រើប្រាស់ផលប្រយោជន៍ក្នុងការធ្វើសំអាងហេតុលើសំណុំរឿង ០០២ ឲ្យស្របតាមសំអាងហេតុរបស់ខ្លួនក្នុងសំណុំរឿង ០០១ ពុំមែនជារឿងសំខាន់ឡើយ។ ការស្តែងឲ្យឃើញថាពួកគាត់ មានផលប្រយោជន៍លើសលុបក្នុងការធ្វើដូច្នេះ នឹងនាំឲ្យមនុស្សម្នាក់ដែលមានសុភវិនិច្ឆ័យ យល់ច្បាស់ថាចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀង។

## ខ. ការចូលរួមនៃបណ្តឹងជំទាស់ចិត្តរបស់ អៀង ធីរិទ្ធ សុំឲ្យគណៈកម្មាធិការរដ្ឋបាលតុលាការបង្កើតអង្គជំនុំជម្រះពិសេសមួយដើម្បីពិចារណា និងសម្រេចលើបណ្តឹងជំទាស់ចិត្ត

១៤. វិធាន ៣៤(៦) ចែងថាសម្រាប់គោលបំណងនៃបណ្តឹងជំទាស់ចិត្ត ចៅក្រមដែលរងការប្តឹងជំទាស់ចិត្ត ត្រូវដកខ្លួនចេញពីការសម្រេចលើបណ្តឹងនោះ។ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង *ត្រូវ* ដកខ្លួនចេញសម្រាប់គោលបំណងនៃបណ្តឹងជំទាស់ចិត្តទាំងនេះ។ នេះជាទម្លាប់អនុវត្តន៍របស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ នៅពេលមេធាវីការពារក្តីស្នើសុំចាត់វិធានការសមស្របទៅលើពួកគាត់ បន្ទាប់ពីមានការបញ្ចេញទស្សនៈរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន[23]។ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងត្រូវអនុវត្តតាមគំរូរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ហើយត្រូវដកខ្លួនចេញពីការសម្រេចលើបណ្តឹងជំទាស់ចិត្ត។

---

[23] *សំណុំរឿងរបស់ អៀង សារី,* 002/19-09-2007-អវតក/(អបជ ០៣), ចម្លើយតបទៅនឹងសំណើរបស់ អៀង សារី ស្នើសុំចាត់វិធានការពាក់ព័ន្ធនឹងទស្សនៈមួយចំនួនរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជំទាស់នឹងឯករាជភាពនៃចៅក្រមអង្គបុរេជំនុំជម្រះ Katinka Lahuis និងចៅក្រម Rowan Downing, ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ERN: 00398615-00398622, កថាខណ្ឌ ២។

### គ. សំណើសុំផ្អាកកិច្ចដំណើរការនីតិវិធី

១៥. វិធាន ៣៤ ពុំតម្រូវឱ្យចៅក្រមដែលត្រូវគេប្តឹងជំទាស់ ដកខ្លួនចេញពីរាល់គ្រប់បញ្ហាទាំងអស់ឡើយ នៅពេលរង់ចាំសេចក្តីសម្រេចស្តីពីបណ្តឹងជំទាស់នោះ។ "ប៉ុន្តែ ចៅក្រមអាចសម្រេចដកខ្លួនដោយស្ម័គ្រចិត្ត ក្នុងដំណាក់កាលណាមួយក្នុងកិច្ចដំណើរការនីតិវិធីខាងក្រោម"[24]។ រហូតដល់ពេលមានការសម្រេចលើបណ្តឹងជំទាស់ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងមិនត្រូវចូលរួមក្នុងបញ្ហាណាមួយដែលរង់ចាំការសម្រេច ឬធ្វើអ្វីមួយដើម្បីត្រៀមរៀបចំលើសំណុំរឿង 00២ ឡើយ ដើម្បីកុំឱ្យបញ្ហាទាំងអស់នោះមានវិការៈ ក្នុងករណីចៅក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវបានប្តឹងជំទាស់នៅពេលក្រោយ។ ដោយហេតុថាបណ្តឹងនេះប្តឹងជំទាស់ចំពោះចៅក្រមតែមួយរូបនៃអង្គជំនុំជម្រះសាលាដំបូង ជាការត្រឹមត្រូវដែលអង្គជំនុំជម្រះសាលាដំបូងត្រូវផ្អាកកិច្ចដំណើរការនីតិវិធីរហូតដល់ពេលបណ្តឹងជំទាស់ត្រូវបានសម្រេចជាស្ថាពរ[25]។

### III. សំណើសុំបើកសវនាការសាធារណៈ

១៦. ការបើកសវនាការផ្ទាល់មាត់ជាសាធារណៈដើម្បីសម្រេចលើបណ្តឹងជំទាស់ គឺជាការចាំបាច់ ។ បណ្តឹងនេះពាក់ព័ន្ធនឹងសិទ្ធិជាមូលដ្ឋានរបស់ លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ពីសំណាក់តុលាការឯករាជ្យមិនលម្អៀង។ គ្មានហេតុផលណាមួយឡើយ ដែលថាបណ្តឹងជំទាស់នេះមិនគួរត្រូវបានតុលាការលើកយកមកពិភាក្សា និងជជែកដេញដោលដោយតម្លាភាពនៅចំពោះមុខសាធារណ

---

[24] វិធាន ៣៤(៥)។

[25] *សូមមើល រដ្ឋអាជ្ញា ទល់នឹង Prlic et al,* IT-04-74-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី Prlic សុំផ្អាកដំណើរការនីតិវិធី, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០។

ជន[26]។ នាពេលកន្លងមក ការខ្វះតម្លាភាព និងការទទួលខុសត្រូវនៅក្នុងជួរ អ.ស.ប បានប៉ះពាល់ដល់ភាពអាចជឿជាក់បានរបស់ខ្លួន ហើយមានការចាត់វិធានការជាបន្តបន្ទាប់ដើម្បីកែខៃស្ថានការណ៍នេះ[27]។ ដូចគ្នានេះ អ.វ.ត.ក គួរចាត់វិធានការដើម្បីធានាឲ្យប្រាកដថាកិច្ចដំណើរការនីតិវិធីរបស់ខ្លួន មានតម្លាភាព ហើយឲ្យអ្នកធ្វើសេចក្ដីសម្រេចរបស់ខ្លួន ចេះទទួលខុសត្រូវ។

**អាស្រ័យហេតុនេះ** ដោយយោងតាមសំអាងហេតុខាងលើ មេធាវីការពារក្ដីរបស់លោក អៀង សារី សូម៖

១. គាំទ្របណ្ដឹងជិតចិត្តត្រង់ចំណុចដែលថា ចៅក្រមអង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀង។

២. ចូលរួមជាមួយបណ្ដឹងរបស់លោកស្រី អៀង ធីរិទ្ធ សុំដកចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដោយដាក់ជំនួសនូវចៅក្រមបម្រុងនៃអង្គជំនុំជម្រះសាលាដំបូង ឬចៅក្រមបន្ថែម ដែលគណៈកម្មា

---

[26] ដូចដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់កាលពីពេលកន្លងមក "មូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានចម្បងនានាក្នុងការបើកសវនាការសាធារណៈគឺដើម្បីឲ្យសាធារណជនត្រួតពិនិត្យមើលភាពត្រឹមត្រូវនៃដំណើរការនីតិវិធី", សំណុំរឿង ខៀវ សំផន, 002/19-09-2007-អវតក/កសចស (អបជ១១), សេចក្ដីសម្រេចលើពាក្យសុំឲ្យមានសវនាការជាសាធារណៈរបស់លោក ខៀវ សំផន, ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨, A190/I/8, ERN: 00236251-00236254។ ដូចដែលគម្រោងយុត្តិធម៌សង្គមសេរីបានកត់សម្គាល់ថា "ការខ្វះការបញ្ជាក់អំពីតម្រូវការចាំបាច់ឲ្យមានភាពសម្ងាត់ក្នុងបញ្ហាជាក់លាក់ណាមួយនោះ វិធានដែលគាំទ្រតម្លាភាពគួរមានអានុភាព ដើម្បីអនុញ្ញាតឲ្យសាធារណជនសង្កេតការងាររបស់តុលាការ", *ការជ្រៀតជ្រែកខាងនយោបាយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*, គម្រោងយុត្តិធម៌សង្គមសេរី, ខែ មិថុនា ឆ្នាំ ២០១០, ទំព័រ ២៧, ("របាយការណ៍ OSJI")។

[27] *សូមមើល* Neil Macfarquhar, អ.ស.ប គាំទ្របេក្ខភាពប្រធានប្រឆាំងអំពើពុករលួយ, International Herald, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១០, ទំព័រ ៣, ដែលប្រធានការិយាល័យសេវាត្រួតពិនិត្យផ្ទៃក្នុង, លោកស្រី Inga-Britt Ahlenius, ត្រូវបានគេរាយការណ៍ថាគាត់បានគូសបញ្ជាក់នៅក្នុងរបាយការណ៍បញ្ចប់ការងារផ្ទៃក្នុងរបស់គាត់ថា នៅ អ.ស.ប (យ៉ាងហោចណាស់ ពាក់ព័ន្ធនឹងការជីកកកាយអំពើពុករលួយផ្នែកហិរញ្ញវត្ថុ) "គ្មានតម្លាភាព, ខ្វះការទទួលខុសត្រូវ"។

ធិការរដ្ឋបាលតុលាការជាអ្នកជ្រើសរើសពីក្នុងចំណោមចៅក្រម អ.វ.ត.ក ដើម្បីពិចារណា និង សម្រេចលើបណ្ដឹងជិតចិត្ត។

៣. ស្នើសុំបើកសវនាការសាធារណៈដើម្បីសម្រេចលើបណ្ដឹងជិតចិត្ត។

សូមលោក/ស្រី ចៅក្រមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៧** ខែ **កុម្ភៈ** ឆ្នាំ **២០១១**